ទំព័រ១ - ដាក់ជូនអង្គប្រជុំលើកទីពីរនៅ ថ្ងៃទី ១៤ ឧសភា ២០១៧ ពិម៉ោង៥-៧ល្ងាច នៅការិយាល័យ រីទ្ធី សៅ

# គម្រោងបង្កើតឃុំសង្កាត់គំរូនៅប្រទេសកម្ពុជាឆ្នាំ២០១៧

ដោយ ពិន សំខុន

‹‹ឃុំសង្កាត់ គឺជាសសរទ្រូងរបស់ប្រជាជាតិ››ប្រជាពលរដ្ឋខ្មែរ នឹងកើនសំណាងច្រើន ប្រសិនបើមានឃុំសង្កាត់យ៉ាងហោចមានចំនួនពាក់កណ្តាល បានត្រូវប្រជាពលរដ្ឋបោះឆ្នោតឱ្យមានមេឃុំជាសមាជិកគណបក្សសង្គ្រោះជាតិ យើងឱ្យឈ្មោះថាជា‹ឃុំសង្កាត់គំរូ›, កន្លងមក ក្នុងចំណោមឃុំសង្កាត់១៦៤៤ មាន‹ឃុំសង្កាត់គំរូ›តែ៤០ប៉ុណ្ណោះដែលគ្រប់គ្រងដោយគណបក្សសង្គ្រោះជាតិ។

ជាង៣០ឆ្នាំកន្លងមកនេះ ប្រជាពលរដ្ឋខ្មែរនៅកម្ពុជា ក្រោមអំណាចដោយគណបក្សប្រជាជនកម្ពុជា បានបាត់បង់‹សំណាងនឹងរស់ជាមនុស្ស› អស់ទៅហើយ ដោយសារតែពលរដ្ឋ គ្មានដីធ្វើស្រែចំការ គ្មានផ្ទះសម្បែងសម្រាប់នៅ នឹងគ្មានការចិញ្ចឹមជីវិតសមរម្យបាន, អ្នកទាំងនោះគ្មានសង្ឃឹមថានឹងបង្ករជាគ្រួសាររឹងប៉ឹងបានទៀតទេ, ‹ស្មារតីជាប្រជាជាតិជឿនលឿន នឹងមានសីលធម៌›ក៏បានរលាយខ្ចាតខ្ចាយ ហើយកំពុងបន្តរលាយតទៅទៀត ប្រសិនបើគ្មានការផ្លាស់ប្តូរទេនោះ។ ដូច្នេះយើងត្រូវនាំគ្នាជួយធ្វើឱ្យការផ្លាស់ប្តូរបបឱ្យកើតឡើងបាន, គឺមិនមែនប្តូរតែគណបក្សនៅក្នុងឃុំសង្កាត់នោះទេ គឺប្តូរជីវភាព នឹងទស្សនៈរបស់ប្រជាពលរដ្ឋ ធ្វើឱ្យទៅជា‹សង្គមនឹងជីវភាពថ្មី››។

អ្នកដែលបានឃ្លាតពីស្រុកទេស មកតាំងទីនៅប្រទេសអាមេរិក តាំងពិ៣០ឆ្នាំមកហើយ មានស្ថានភាពនឹងជីវភាពមាំមួនគ្រាន់បើ បាននឹកទៅដល់អ្នកទាំងនោះជាសាច់ឈាមនៅកម្ពុជា មានបំណងចូលទៅជួយបងប្អូនខ្មែរ ឱ្យមានជិវភាពគ្រាន់បើដោយខ្លួនឯង មានកន្លែងរស់នៅសមរម្យ មានសម្បត្តិល្មមនឹងឱ្យកូនចៅបន្តរៀនសូត្រ នឹងបណ្តុះបណ្តាលសីលធម៌ជឿនលឿនខ្មែរមកវិញ។ គឺមិនមែនជាចលនានយោបាយទេ តែសំដៅទៅជួយពលរដ្ឋជាបន្ទាន់ តាមរយៈអ្នកនយោបាយសេរី។

តាមរយៈអ្នកតំណាងរាស្ត្រនៃគណបក្សសង្គ្រោះជាតិ ទៅពីឡូវែល យើងនឹងបញ្ជូនភ្នាក់ងារពីសហរដ្ឋអាមេរីកទៅជួយឃុំសង្កាត់ដែលយកបានថ្មីៗ ឱ្យចេញពីស្ថានភាព‹អូនថយ› ឱ្យមានជំនឿជាថ្មីថា‹បងប្អូនខ្មែរនឹងមានសំណាងច្រើននៅពេលដែលឃុំបងប្អូនទាំងនោះនៅខាងគណបក្សសង្គ្រោះជាតិ›គឺយើង‹ប្រាថ្នានឹងជួយ›ឱ្យជីវភាពបងប្អូន ឱ្យផ្លាស់ជាប្រសើរមិនឱ្យត្រឡប់ក្រោយវិញឡើយ។

១-បង្កើនផលិតផលកសិកម្មគ្រួសារ, បង្កើនការថែរសុខភាព, ណែនាំពីរបៀបគ្រប់គ្រងផ្ទះសម្បែងទំនើប

អប់រំបរិដ្ឋានគ្រួសារថ្មី, ទំនាក់ទំនងវត្តអារាម  នឹងទំនាក់ទំនងឃុំសង្កាត់ ដើម្បីអភិវឌ្ឍន៍រួម

៣-ការកសាងអនាគតលើការសិក្សារបស់យុវជន យុវនារី គិតគូរពិការសន្សំ, ថែរទាំចាស់ជរា ឱ្យមានការចូលនិវត្តន៍។

ពីអាមេរិកនេះ ទៅជួយបងប្អូន គឺ -បង្ករលក្ខណៈសីលធម៌  យុត្តិធម្ម នឹងសមធម៌ ដែលជាមូលដ្ឋានគ្រឹះ នៃសហគមន៍ដែលគោរពសិទ្ធិមនុស្ស ហើយម្នាក់ៗអនុវត្តន៍នូវសកម្មភាព ជួយអ្នកដ៏ទៃដោយមិនរើសមុខ។

ឯកឧត្តម ង៉ោ គិមឈៀង តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិតំបន់កំពុងឆ្នាំង ដែលទៅពីក្រុងឡូវែលនេះទៅ បានឱ្យដំណឹងថា‹នៅកំពុងឆ្នាំងមានឃុំចំនួន៧០ ដែលត្រូវជ្រើសរើស មេឃុំ-ជំទប់ នឹងគណកម្មការឃុំចំនួនទាំងអស់យ៉ាងតិច ៣៥០រូប, ‹ក្នុងចំនួននោះ មេឃុំគណបក្សសង្គ្រោះជាតិមានតែ១គត់ នៅមានមេឃុំចំនួន៦៩រូបទៀត ជារបស់គណបក្សប្រជាជនកម្ពុជា›។

ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ ឈរជាបេក្ខជនដំណាងរាស្ត្រសម្រាប់ខេត្រព្រះសីហនុ បានមានព្រះបន្ទូលកាលពីពលរដ្ឋឡូវែលបានទទួលព្រះអង្គនាខែមិនា២០១៧នោះថា‹ខេត្រព្រះសីហនុ មិនមានមេឃុំឬចៅសង្កាត់ណាម្នាក់មកពីគណបក្សសង្គ្រោះជាតិនៅឡើយទេ› ប្រសិនបើយើងចង់ជួយកំពុងឆ្នាំង នឹងខេត្រព្រះសីហនុ យើងត្រូវធ្វើឱ្យឃុំទាំងអស់ក្លាយជា‹របបគ្រប់គ្រងសេរី ប្រសើរ នឹងគ្រប់គ្រាន់› ទើបពលរដ្ឋអាចមានជីវិតរស់នៅពេញសិទ្ធិបាន ។

នាឱកាសបោះឆ្នោតខែមិថុនា២០១៧ខាងមុខនេះ គ្រប់អ្នកសង្កេតការបានទស្សន៍ទាយថា‹គណបក្សសង្គ្រោះជាតិនឹងឃើញឃុំនឹងសង្កាត់របសគណបក្សខ្លួនកើនចំនួនគួរកត់សំគាល់› ព្រះអង្គម្ចាស់ ធម្មោកោ នឹង ឯកឧត្តម ង៉ោ គឹមមៀង ក៏មានយោបល់ស្របនឹងការទស្សន៍ទាយនេះដែរ។ ហេតុនេះហើយបានជាសហគមន៍យើងនៅក្រៅប្រទេស ត្រូវប្រមូលកម្លាំងតបស្នងសងគុណប្រជាជាតិយើង ដោយថែររក្សាឃុំនឹងសង្កាត់ដែលបានដូរដៃ ពីគណបក្សប្រជាជនកម្ពុជាមកសង្គ្រោះជាតិ នាខែមិថុនានោះឱ្យជាប់ ពីព្រោះវាជាច្រកដ៏ចង្អៀត ដែលអ្នក‹ប្រាថ្នានឹងជួយ›បងប្អូនខ្មែរ ដោយរៀបចំគម្រោងសកម្មភាព‹នយោបាយចិត្តសាស្ត្រយកឈ្នះចិត្តប្រជាពលរដ្ឋឃុំសង្កាត់គំរូយើង› កុំឱ្យត្រឡប់ទៅគណបក្សប្រជាជនបានវិញឱ្យសោះ។

តើយើងនឹងធ្វើអ្វីខ្លះ?

**ទំព័រ ៣**

## ក - សកម្មជន‹នយោបាយចិត្តសាស្ត្រ-បង្កើតឃុំសង្កាត់គំរូកម្ពុជា›

**ក១-មានភារៈកិច្ចៈ** គឺជាបុគ្គលស្ម័គ្រចិត្ត ត្រៀមខ្លួនទៅជួយឃុំសង្កាត់ដែលនៅក្នុងចង្កោមឃុំសង្កាត់របស់គណបក្សសង្គ្រោះជាតិ តាមទីកន្លែងដែលខ្លួនឈរជើង ជាសកម្មជនជួរក្រោយ (គឺនៅអាមេរិក) ឬជាសកម្មជនជួរមុខ(គឺនៅកម្ពុជា)។

មុខព្រួញពាដែលត្រូវលើកយកមកអនុវត្តន៍ជា‹បន្ទាន់› នឹងដោយមាន‹ជំនាញ›

ក១១-បង្កើតធានាគារម្ហូបអាហារ នឹង ថ្នាំសង្កូវសម្រាប់ជួយដល់ពលរដ្ឋដែលត្រូវការជំនួយចាំបាច់ សម្រាប់រស់នៅ

ក១២-បង្កើនបណ្តាញទទួលពត៏មានសុខភាពប្រញាប់ សម្រាប់ទទួលជំនួយសង្គ្រោះបន្ទាន់

ក១៣-បង្កើតមជ្ឈមណ្ឌលពិគ្រោះយោបល់: នយោបាយ សីលធម៌ សេដ្ឋកិច្ច សុខភាព នឹង សារពត៏មាន

**ក២-ភារកិច្ចសកម្មជនជួរក្រោយៈ** (សមាជិកនៅអាមេរិក)

ក២១- ស្វែងរកសមាជិកដែលស្ម័គ្រចិត្ត ចូលជាវិភាគទានប្រចាំខែដល់អង្គភាព‹នយោបាយចិត្តសាស្ត្រយកឈ្នះចិត្តប្រជាពលរដ្ឋឃុំសង្កាត់គំរូយើង›

ក២២-ចូលរួមជា‹សមាជិគណកម្មការជួរក្រោយ›សម្រាប់បំពីឃុំសង្កាត់នៅខេត្តណាមួយ

ក២៣-សិក្សានឹងពង្រឹងស្មារតីបំពីជាសកម្មជន‹ នយោបាយចិត្តសាស្ត្រយកឈ្នះចិត្តប្រជាពលរដ្ឋឃុំសង្កាត់យើង›

**ក៣-ភារៈកិច្ចសកម្មជនជួរមុខៈ** (សមាជិកនៅកម្ពុជា)

គឺអ្នកដែលទៅធ្វើការនៅកម្ពុជា ឬក៏ រស់នៅកម្ពុជា(ក្រៅក្របខណ្ឌ)ទៅធ្វើការសហការជាមួយមេឃុំ ឬ ចៅសង្កាត់គណបក្សសង្គ្រោះជាតិ នៅកំពុងឆ្នាំង ឬ នៅខេត្តព្រះសីហនុ កសាង‹សន្តិសុខសង្គម›ឱ្យមានជីវភាព ស្មើនឹងគ្រប់គ្រាន់..

ក៣១- ផ្នែកនៅនឹងកន្លែងឈរជើង‹Static› ជាទីស្នាក់ប្រចាំការ ជាឃ្លាំងស្តុកផលិតផល ជាកន្លែងដាក់សម្ភារៈ ជាបណ្ណាល័យ ជាមណ្ឌលសម្រាប់ពលរដ្ឋមកទាក់ទងសេរី...

ក៣២- គឺជាផ្នែកចេញទៅជួបប្រស្រ័យទាក់ទងនឹងពលរដ្ឋ ‹Outreach›សម្រាប់ពន្យល់នឹងឱ្យយោបល់ ធ្វើកសិកម្ម រកទីផ្សារឱ្យកសិករ ធ្វើពីសេដ្ឋកិច្ច-សុខភាព-អប់រំគ្រួសារ ពិនយោបាយប្រទេសសេរី ពីពិភពលោក ពីទំនាក់ទំនងសាធារណ ធ្វើសារពត៌មាន...

## ខ - រចនាសម្ព័ន្ធ‹‹សកម្មជនជួរក្រោយ››

**ខ១-គោលបំណង:** គឺបង្កើតជាអង្គភាព‹មូលនិធិនៅឡូវែលសហរដ្ឋអាមេរិក›មួយ ដើម្បីទៅជួយ‹ឃុំនឹងសង្កាត់›នៅកម្ពុជា ក្នុងតំបន់ដែលបានកំណត់ (គឺខែត្រព្រះសីហនុ នឹង ខែត្រកំពុងឆ្នាំង) ហើយដែលមាន‹មេឃុំឬចៅសង្កាត់›នៅក្នុងការគ្រប់គ្រងនយោបាយរបស់គណបក្សសង្គ្រោះជាតិ ឱ្យមានលទ្ធភាពនឹងធ្វើការប្រកបដោយប្រសិទ្ធិភាព ជូនប្រជាពលរដ្ឋនៅក្នុងឃុំសង្កាត់របស់ខ្លួន។

ចំណុច៣ដែលត្រូវផ្តល់ការឧបត្ថម្ភ ចាប់តាំងពីឃុំសង្កាត់បាន ទទួលការប្រកាសលទ្ធផលថាជា‹កូតា›របស់គណបក្សសង្គ្រោះជាតិ: ១-បង្កើនធានាគារ‹ចំណីអាហារ›ឱ្យមានភាពគ្រប់គ្រាន់ គាំទ្រដល់អ្នកដែលត្រូវការបំផុត ២-បង្កើងការផ្តល់សង្គ្រោះបន្ទាន់ដល់‹សុខភាព› មនុស្សចាស់ជរា ស្ត្រី កុមារ នឹងពលរដ្ឋក្រីក្រ ៣-បង្កើនមធ្យោបាយផ្តល់ពត៏មានចាំបាច់ដល់ប្រជាជន ផ្តល់ការអប់រំ ផ្តល់មធ្យោបាយទំនាក់ទំនងទៅមករវាងពលរដ្ឋនឹងម្ចាស់ជំនួយនៅសហរដ្ឋអាមេរិក។

**ខ២-រយពេលកំណត់:** ១ឆ្នាំ ឬ ធ្វើការបន្តរទៅទៀតទៅតាមសេចក្តីសម្រេចរបស់គណកម្មការនាយក

**ខ៣-សមាជិកភាព** សមាជិករបស់មូលនិធីមាន 5 ប្រភេទ:

**១-សមាជិកសកម្ម** គឺជា‹សមាជិកមានសិទ្ធបោះឆ្នោតនៅក្នុងសកម្មភាពសមាគម›ទាំងមូល សមាជិកនោះបង់វិភាគទានជូនមូលនិធី ២០ដុល្លា ក្នុងមួយខែ ហើយសន្យាថាគោរព-កាពារនឹងលើកដំកើងលក្ខន្តិកៈមូលនិធិរបស់ខ្លួន។

**២-សមាជិកគាំទ្រ** ជាសមាជិកដែលបានជួយជាវិភាគទានជាប្រាក់ ឬ ជារបស់(ម្តង ឬ ច្រើនដង) ដើម្បីជួយសកម្មភាពមូលនិធិ  មិនមានសិទ្ធបោះឆ្នោត ជជីសតាំងអ្នកគ្រប់គ្រងទេ

**៣-សមាជិកកិត្តិយស** គឺជាសមាជិកដែលផ្តល់ជាប្រយោជន៍ ឬ ជារបស់ ឬ ជាប្រាក់ ដ៏ធំធេងដល់មូលនិធីហើយទទួលនូវប័ណ្ណកោតសសើរកិត្តិយសពីគណកម្មកានាយក មិនមានសិទ្ធបោះឆ្នោត ជ្រើសតាំងអ្នកគ្រប់គ្រងទេ។

**៤-សមាជិកស្ថាបនិក** គឺជាសមាជិក‹សកម្មអចិន្ត្រៃ› ជាអ្នកចូលរួមបង្កើត នឹងចូលរួមធ្វើឱ្យមូលនិធិមានដំណើរការប្រសើរបាន ។ សមាជិកស្ថាបនិក ត្រូវទទួលការគាំទ្រពីមហាសន្និបាតទី១ របស់មូលនិធិ មិនមានសិទ្ធបោះឆ្នោត ជ្រើសតាំងអ្នកគ្រប់គ្រងទេ តែមានតួរនាទីជា‹ទីប្រឹក្សាអចិន្ត្រៃយ៍›របស់សមាគម ។

ការបាត់បង់សមាជិកភាពណាមួយ ត្រូវទទួលការសម្រេចពីគណកម្មការនាយក ឬ សម្រាប់សមាជិកសកម្មគឺនៅពេលខានបង់វិភាគទាន៣ខែជាប់គ្នា ឬ ទទួលមរណភាព។

**៥-សកម្មជន:** គឺជាសមាជិក ឬ ក៏អ្នកស្ម័គ្រចិត្តក្រៅពីរង្វង់សមាជិក ដែលប្រធានឃុំ-ខេត្រ អនុញ្ញាត្តឱ្យចូលរួមសកម្មភាពសម្រាប់‹សកម្មភាពនៅជួរមុខ› នឹង ប្រធានប្រតិបត្តិអនុញ្ញាត្តិសម្រាប់ជួរក្រោយ។

**ខ៤-មហាសន្និបាត** មាន២យ៉ាង គឺមហាសន្និបាតសាមញ្ញ នឹង មហាសន្និបាតវិសាមញ្ញ

**ខ៤១-មហាសន្និបាតសាមញ្ញ** ជាកិច្ចប្រជុំសមាជិកទាំងអស់ ធ្វើ១ឆ្នាំម្តង លើកទី១ ត្រូវធ្វើនៅខែសីហា ឆ្នាំ ២០១៧ សម្រាប់តែងតាំង សមាជិកស្ថាបនិក, តែងតាំងគណកម្មការនាយក(៧រូប)ដែលជាអ្នកជ្រើសរើសប្រធានសមាគមបន្ទាប់ភ្លាមមក នឹងស្នងការគណនេយ្យ(១រូប), គណកម្មការនាយកនេះ តែងតាំងនាយកប្រតិបត្តិ(១រូប) នឹងតែងតាំងអគ្គហិរញ្ញិក នឹង ហិរញ្ញិករង(ទាំង២រូប)ទាំងអស់មកពីសមាជិកសកម្ម។

<u>គណកម្មការនាយក</u> មានភារកិច្ចតែងតាំង ‹តំណាងប្រទេស›មានកាងារនៅកម្ពុជានឹងអាមេរីក, យល់ព្រមការតែងតាំង‹តំណាងខេត្រ› នឹងតំណាងឃុំ-សង្កាត់ តាមការស្នើរបស់‹តំណាងប្រទេស›

**ខ៤២-មហាសន្និបាតវិសាមញ្ញ** ជាកិច្ចប្រជុំសមាជិកទាំងអស់ តាមកាលបរិច្ឆេតដែលប្រធានគណកម្មការនាយកអញ្ជើញ ដើម្បីសម្រេចបញ្ហាសំខាន់ៗទាំងឡាយណា ដែលមិនមានអាណត្តិកំណត់

**ខ៤៣-សេចក្តីសម្រេចរបស់មហាសន្និបាត** យកជាបានការ គឺសមាជិកច្រើនជាង៥០% - សម្រាប់ប្តូរមាត្រាណាមួយនៃលក្ខន្តិកៈ ត្រូវមានសម្លេងយល់ព្រមលើស២ភាគ៣។

<u>ការកោះប្រជុំមហាសន្និបាតលើកទី១</u> អាចយកជាបានការ លុះត្រាតែមានសមាជិកពាក់កណ្តាលមកចូលរួម, បើមិនគ្រប់ចំនួននេះទេ ប្រធានគណកម្មការនាយកអាចកោះប្រជុំជាលើកទី២ ចំនួនសមាជិកមកប្រជុំតិចជាង ៥០% ក៏សម្រេចយកជាការបានដែរ។ ការបោះឆ្នោតផ្ញើរសម្លេង អាចទទួលយកបាន។

<u>អង្គការលេខ:</u> មហាសន្និបាត

គណកម្មការនាយក

នាយកប្រតិបត្តិ

នាយករង

អគ្គហិរញ្ញិក <----------> ស្នងការគណនីយ នឹង ស្នងការរង

ហិរញ្ញិករង

## គ-រចនាសម្ព័ន្ធសកម្មជនជួរមុខ (ធ្វើការនៅប្រទេសកម្ពុជា)

គួររំលឹកថា កាងារដែលធំសម្រាប់អង្គភាព គឺបំរើចិត្តសាស្ត្រឃុំនឹងសង្កាត់ថ្មី(ជាប់ឆ្នោតនៅខែមិថុនា ២០១៧) ដែលទើបនឹងរំដោះចេញពីការគ្រប់គ្រងរបស់គណបក្សប្រជាជន ហើយដែលមិនទាន់បានធ្វើអ្វីសម្រាប់លើកដំកើងប្រជាពលរដ្ឋជនបទ របស់ខ្លួននៅឡើយ ដោយប្រមូលកម្លាំងពីក្រៅប្រទេស ទៅជួយស្រុកខ្មែរដែលដុនដាប ដែលប្រជាពលរដ្ឋខ្មែរយើងមានសេចក្ដីក្លាហានបោះឆ្នោតឱ្យគណបក្សសង្គ្រោះជាតិ កុំឱ្យបែរជាខកចិត្ត ហើយត្រឡប់ទៅក្នុងដៃគេវិញបាន, គឺប្រមូលចំណេះ ប្រមូលបទពិសោធន៍ ប្រមូលធនធាន នឹងជំនឿយ៉ាងមុតមាំ ទៅកែរប្រែសង្គមចាស់ពុករលួយ ឱ្យទៅជាសង្គមសីលធម៌ នឹង រីកចំរើន។

**គ១-ដំណាងប្រទេស** មានអាណត្តិ១ឆ្នាំ តែងតាំងដោយគណកម្មការនាយក តាមការស្នើររបស់ប្រធាន: មានតួរនាទីរៀបចំទទួលអ្នកស្ម័គ្រចិត្តទៅពីអាមេរីក - ប្រស្រ័យទាក់ទងនឹងតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ - ណែនាំកម្មវិធីសង្គមកិច្ចនឹងសេដ្ឋកិច្ច ដែលខាងអាមេរីកដាក់ឱ្យធ្វើយកទៅអនុវត្តន៏ដោយប្រុងប្រយ័ត្ន - គ្រប់គ្រងតំណាងខែត្រឱ្យបំពេញកាងារបានល្អ - ជាអ្នកត្រួតពិនិត្យថវិកា បែងចែកថវិការទៅឱ្យដំណាងខេត្រ នឹង ត្រួតពិនិត្យការចាយវាយរបស់ថ្នាក់ក្រោម - រាយការណ៍ពីលទ្ធផលកាងារក្នុងប្រទេស មកប្រធានប្រតិបត្តិរៀងរាល់សប្តាហ៍

**គ២-ដំណាងខេត្រ** មានអាណត្ត១ឆ្នាំ តែងតាំងដោយគណកម្មការនាយក តាមការស្នើររបស់ប្រធាន: ជាអ្នកគ្រប់គ្រងសកម្មជនទាំងអស់ - ជាអ្នកគ្រប់គ្រងកាងារដែលផ្ដល់ឱ្យដំណាងឃុំនឹងសង្កាត់ - ជាអ្នកចុះ

**ទំព័រ ៧**

ហត្ថលេខាអនុញ្ញាតឱ្យដំណាងឃុំនឹងសង្កាត់ចាយវាយថវិការដែលផ្តល់ទៅឱ្យ - រាយការជាវៀងរាល់សប្តាហ៍មកដំនាងប្រទេស នឹង លេខាដ្ឋានប្រធានមូលនិធិ

**គ៣-ដំណាងឃុំ ឬ សង្កាត់:** មានអាណត្ត១ឆ្នាំ តែងតាំងដោយគណកម្មការនាយក តាមការស្នើររបស់ប្រធានដោយមានការពិគ្រោះជាមួយតំណាងប្រទេស នឹង តំណាងខែត្រ - ជាអ្នកចាត់ចែងផ្ទាល់ដៃលើគម្រោង ១-ធ្វើកសិកម្មបង្កើតម្ហូបអាហារក្នុងឃុំ - ២-គម្រោងថែរទាំសុខភាពសង្គម ៣-គម្រោងបង្កើតបណ្តាញទំនាក់ទំនងនឹងផ្សព្វផ្សាយមាកអាមេរីកវិញ។ ធ្វើការដោយមានការពិគ្រោះជាមួយគណកម្មការឃុំសង្កាត់ ដើម្បីអភិវឌ្ឍន៍តំបន់របស់ខ្លួន - ចងគ្នាជាចង្កោមគ្រប់គ្រងរួមគ្នា ៣ឃុំជាប់គ្នាជាចង្កោមតែមួយ - ដាក់ថវិការចូលគ្នា - ដោះស្រាយបញ្ហាក៏រួមមតិគ្នា។

## ឃ-គម្រោងរកធនធាន - ប្រាក់ចំណូលនឹងចំណាយ

**ឃ១-ធនធាននឹងប្រាក់ចំណូល:** គឺជាសម្បត្តិរបស់អង្គការ‹មូលនិធីឃុំសង្កាត់សង្គ្រោះជាតិ› ដែលនឹងធ្វើឱ្យអង្គការនេះមានដំណើរការទៅបាន គេអាចរាប់ពី: ធនធានមនុស្ស - របស់របរចលនឬអចលនៈវត្ថុ នឹង លុយកាក់, ដែលបានមកពី:

- **សមាជិកសកម្ម** សមាជិកម្នាក់បង់ ២០ ដុល្លា ក្នុងមួយខែ មានរយៈពេលមួយឆ្នាំ (មានគម្រោងរកសមាជិកសកម្មឱ្យបាន១,០០០នាក់ ត្រូវនឹងប្រាក់ចំណូល ២០,០០០ ក្នុងមួយខែ...)
- **អំណោយពីសប្បុរសជន** អំណោយនានាបានមកពិ‹សមាជិកគាំទ្រ›នឹង‹សមាជិកកិត្តិយស› (មានគម្រោងរកសមាជិកគាំទ្រឱ្យបាន៥,០០០នាក់ ដែលនឹងផ្តល់ប្រាក់ចំណូល ១០០,០០០ ២ដងក្នុង១ឆ្នាំ)
- **ការរៃអង្គាស** ធ្វើពិធីបុណ្យផ្កា រាត្រីសមោសរ លក់ឆ្នោតវត្ថុ ឬ វត្ថុអនុស្សាវរីយ៍...(មានគម្រោងរកឱ្យបាន ១០០,០០០ក្នុងមួយឆ្នាំ)

**ឃ២-គម្រោងចំណាយ:**

-ទីស្នាក់ការនៅអាមេរីក បុគ្គលិកប្រចាំការ

—ទឹក, ភ្លើង, ទូរស័ព្ទ

—សេវា(បោះពុម្ភ រដ្ឋបាល មេធាវី)

—ផ្តល់ទៅឃុំសង្កាត់និមួយៗ ១,០០០ដុល្លា ក្នុងមួយខែ

—ធ្វើដំណើរ

—ការដ្ឋាន បង្ហាត់ហ្វឹកហ្វឺន

(យោងតាមលទ្ធផលនៃការបោះឆ្នោត ចាប់ពីខែសីហា ២០១៧

កំពុងឆ្នាំងបានឃុំ៨ មានមេឃុំជាគណបក្សសង្គ្រោះជាតិ ប្រើសកម្មជន ៨នាក់ ចំណាយ៨,០០០មួយខែ,

រីឯខេត្រព្រះសីហនុ បានឃុំនឹងសង្កាត់៣ ប្រើសកម្មជន ៣នាក់ ចំណាយ ៣,០០០មួយខែ

ត្រូវរកប្រាក់ចំណូលឱ្យបាន យ៉ាងតិច ១១,០០០ ក្នុន១ខែ។)

(ចាប់ពីខែកុម្ភៈ២០១៨ទៅ គឺ៦ខែបន្ទាប់មក ទៅដល់ខែកក្កដា, ថវិការនឹងចុះមកត្រឹមតែ៥០០ដុល្លាក្នុងមួយខែ

វិញ សម្រាប់១ឃុំ យោងតាមកសិដ្ឋានកំពុងតែបញ្ចេញផល មកជួយម្ហូបអាហាក្នុងឃុំសង្កាត់បានហើយ,

ខែត្រកំពុងឆ្នាំង នៅសល់ចំណាយ៨ឃុំ តែ៤,០០០ដុល្លា

ខេត្រព្រះសីហនុ នៅសល់ចំណាយលើឃុំ តែ ១,៥០០ដុល្លា )

(សរុបចំណាយប្រចាំឆ្នាំ ៦ខែដំបូង ១១,០០០ * ៦ = ៦៦,០០០

ចំណាយ ៦ខែបន្ទាប់ ១២,៥០០ * ៦ = ៦,២៥០

ក្នុង១ឆ្នាំចំណាយឃុំសង្កាត់ទាំងអស់ ............២៧,២៥០ ដុល្លា)

សកម្មជនស្ម័គ្រចិត្ត នឹងបន្តសកម្មភាព‹ប្តូរដៃ›បន្ថែម តាំងពិដើមឆ្នាំ២០១៨ រហូតដល់បោះឆ្នោតសភាចប់សព្វគ្រប់ ជាមួយនឹងថវិការថ្មីទៀត ដើម្បីឱ្យពលរដ្ឋក្នុងស្រុក អាចបន្តរ‹ធ្វើការប្រកបដោយសិលធម៌នឹងបច្ចេកទេសមកពិអាមេរីក›បាន។

រយពេលចុងក្រោយនោះ ណែនាំប្រជាពលរដ្ឋក្នុងឃុំ នឹងសង្កាត់ឱ្យចេញទៅឃោសនា ហ៊ានបង្ហាញពីហេតុផល‹ត្រូវ-ខុស›ជាសាធារណ នឹង ដោយសេរី ឱ្យទាល់តែបានដំណាងរាស្ត្រដែលខ្លួនឯងចង់បាន ដែលខ្លួនជឿជាក់ថាដំណាងរាស្ត្ររបស់ខ្លួន មានស្មារតី‹ប្រាកដជាបំរើពលរដ្ឋខ្មែរ មិនក្លែងក្លាយ›ឡើយ៕

អ្នកដែលបានចូលរួមប្រជុំកែរគម្រោងនេះ ថ្ងៃទី ៦ឧសភា២០១៧ វេលាម៉ោង ៥-៧ល្ងាច មាន:

- ប្រាហ៊ីម កែ
- រីទ្ធី សៅ
- ពិន សំខុន រ៉ដ៍រ
- គ្នារី ហ៊ុន
- សារី ឯម
- សុកផល ប៉ែន

មិនបានមករួមប្រជុំ

- ស៊ីទ្ធួន ខាំ
- រីទ្ធី អ៊ុង
- សារីទ្ធ ស្រី
- ប៉ាន សូ
- គឹមលី ជា

លើកក្រោយសម្រេចមករួមប្រជុំ ថ្ងៃទី ១២ឧសភា២០១៧ វេលាមោង៥-៧ ល្ងាច នៅការិយាល័យ រីទ្ធី សៅ ៕

ទំព័រ ១០ – បញ្ចប់

# បង្រួមសេចក្ដី

១-អត្ថន័យៈ រួមប្រជុំពលរដ្ឋដើមកំណើតខ្មែរនៅសហរដ្ឋអាមេរិក ដើម្បីទៅជួយជា‹គំរូ›ក្នុងរយពេល១ឆ្នាំ ដោយមិនធ្វើនយោបាយ ជួយដល់ពលរដ្ឋខ្មែរនៅឃុំសង្កាត់នៃខេត្តកំពុងឆ្នាំង នឹងខេត្តព្រះសីហនុ ឱ្យបានប្ដូរជីវភាពប្រសើរឡើង តាមរយៈឃុំសង្កាត់របស់គណបក្សសង្គ្រោះជាតិ បន្ទាប់ពីបោះឆ្នោតឃុំនឹងសង្កាត់ នៅតំបន់ទាំងពិរនោះរួច។

២-រចនាសម្ព័ន្ធបង្កើតមូលនិធី សម្រាប់ជួយ ‹**បង្កើតមូលនិធិឃុំសង្កាត់គំរូនៅកម្ពុជា-CDF**›

- គណកម្មការនាយក១០រូប អាណត្តិ២ឆ្នាំ បណ្ដោះអាសន្ន (សម្រាប់រៀបបោះឆ្នោតនៅ៣ខែខាងមុខ)
- ប្រធានប្រតីប័ត្ត មានអាណត្តិ១ឆ្នាំ បណ្ដោះអាសន្ន (តែងតាំងនៅ៣ខែខាងមុខដោយគ.ក.នាយកថ្មី)
- អគ្គហិរញ្ញឹក នឹង ហិរញ្ញឹករង មានអាណត្តិ១ឆ្នាំ តែងតាំងបណ្ដោះអាសន្នសម្រាប់៣ខែ ដោយប្រធានប្រតីប័ត្ត
- ស្នងការគណនេយ្យ មានអាណត្តិ១ឆ្នាំ (ដោយការបោឆ្នោតក្នុងមហាសន្និបាតសាមញ្ញ)

<u>សកម្មជនជួរមុខ</u>

- តំណាងប្រទេស អាណត្តិ១ឆ្នាំ តែងតាំងដោយប្រធានប្រតិបត្តិ យលព្រមដោយ គ.ក.នាយក
- តំណាងខេត្ត - ដូចគ្នា -
- តំណាងសង្កាត់គំរូ នឹងតណាងឃុំគំរូ - ដូចគ្នា -

៣- កម្មវិធិ៣មុខ ជាជំនួយដល់ឃុំសង្កាត់គំរូ របស់‹សកម្មជនជួរមុខ›

- ជំនួយសម្រាប់បង្កើនម្ហូបអាហារឱ្យបានគ្រប់គ្រាន់ជាបន្ទាន់
- ជំនួយបន្ទាន់ដល់សុខភាព នឹង ផាសុខភាព ចាំបាច់របស់គ្រួសារ
- ជំនួយបង្កើតបណ្ដាញទំនាក់ទំនង‹សេរី›នៅឃុំសង្កាត់គំរូ សម្រាប់កាពារ អប់រំ ពង្រីករង្វង់រកជំនួយ ៕

* * * * *